ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សូមគោរពជម្រាបជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

**កម្មវត្ថុ៖** សូមគោរពជូនរបាយការណ៍ ស្តីពីស្ថានភាពនៃអំពើជួញដូរមនុស្ស ការវាយតម្លៃប្រចាំឆ្នាំពីសហរដ្ឋអាមេរិក និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់

អំពើជួញដូរមនុស្ស គឺជាបទល្មើសដែលមានរចនាសម្ព័ន្ធសាំញ៉ាំ ប្រទាក់ក្រឡាក្ញុបផ្សំជាមួយឧក្រិដ្ឋកម្មជាច្រើនទៀត ដែលពិភពលោក បាន និងកំពុងនាំគ្នារិះរកវិធីដោះស្រាយ ស្របពេលដែលបច្ចេកវិទ្យាព័ត៌មាន កំពុងតែត្រូវបានប្រើប្រាស់ ទាំងក្នុងប្រព័ន្ធរដ្ឋបាល ទាំងក្នុងប្រព័ន្ធឧក្រិដ្ឋជនក្នុងការប្រព្រឹត្តបទល្មើស ។ មួយចំនួនធំកើតមាននៅក្រៅប្រទេសដែលជាអំពើជួញដូរ និងកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ផ្លូវភេទ និងពិបាកដោះស្រាយក្នុងការជួយជនរងគ្រោះតាមប្រព័ន្ធច្បាប់ នៅពេលដែលជនរងគ្រោះ ស្ថិតក្នុងស្ថានភាព ខុសច្បាប់ គ្មានអត្តសញ្ញាណច្បាស់លាស់ ឬត្រូវបានគេប្តូរអត្តសញ្ញាណ ។ ថ្វីត្បិតតែមានអនុស្សរណៈ ឬកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធមួយចំនួន តែការអនុវត្ត នៅតែមានភាពប្រឈម ដោយមូលហេតុការផ្អែកលើច្បាប់តាមប្រទេស និងការពារផលប្រយោជន៍ជាឯកត្តោភាគី ។ ហេតុនេះ កិច្ចប្រតិបត្តិការ ទាមទារឲ្យស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល មានការប្តេជ្ញាចិត្ត ឆន្ទៈមុះមុត និងឯកភាពគ្នាក្នុងឧត្តមគតិការពារផលប្រយោជន៍ជាតិ និងប្រជាជន ដោយស្រុសដៃគ្នា សហការគ្នា មិនអាចក្រសួង ឬស្ថាប័នតែមួយ អាចដោះស្រាយបញ្ហានេះបានដោយឯកឯងឡើយ ។ ហេតុនេះហើយ បានជា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសេនាធិការជូនរាជរដ្ឋាភិបាល ខិតខំពុះពារគ្រប់ឧបសគ្គពង្រឹងការចូលរួម សហការ ក្នុងនាមជាយន្តការជាតិ ដើម្បីធ្វើជាកម្លាំងសរុប ធនធានសរុប មធ្យោបាយសរុប ដោះស្រាយបញ្ហាបទល្មើសជួញដូរមនុស្សគ្រប់រូបភាព ដោយផ្តោតលើកិច្ចសហការក្នុងការបង្ការទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូបភាព ឲ្យអស់ពីលទ្ធភាព និងសមត្ថភាព រហូតទទួលបានការទទួលស្គាល់ពីអង្គការសហប្រជាជាតិ ជាពិសេស អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅទីក្រុង ហ្សឺណែវ ដាក់បញ្ចូលកម្ពុជា ក្នុង

បញ្ជីនៃប្រទេសជ័យលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលជាគោលការណ៍សាកលការពារជនទេសន្តរប្រវេសន៍ពីការកេងប្រវ័ញ្ច អំពើហិង្សា និងការជួញដូរមនុស្ស ។

## ១. ការវាយតម្លៃពីសហរដ្ឋអាមេរិក

កម្ពុជា បានទទួលការវាយតម្លៃពីសហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ២ ក្នុងបញ្ជីឃ្លាំមើល ពីរឆ្នាំជាប់គ្នា គឺ ឆ្នាំ២០១៩ និងឆ្នាំ២០២០ (ឆ្នាំ ២០១៦, ២០១៧ និង ២០១៨ កម្ពុជា មានចំណាត់ថ្នាក់លេខ២) ។

ការកំណត់ចំណាត់ថ្នាក់របស់អាមេរិក

សូមគោរពជម្រាបជូនសម្តេចមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ចំណាត់ថ្នាក់ ដែលអាមេរិកកំណត់សម្រាប់វាយតម្លៃបណ្តាប្រទេសក្នុងពិភពលោក មានបួនកម្រិត គឺ លេខ១ លេខ២ លេខ២ក្នុងការឃ្លាំមើល និងលេខ៣ ។

- **ប្រទេសដែលមានចំណាត់ថ្នាក់លេខ១៖** ជាប្រទេស ដែលអនុវត្តពេញលេញនូបទដ្ឋានអប្បបរមា នៃច្បាប់ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ឬបស់អាមេរិក)សម្រាប់ការលុបបំបាត់អំពើជួញដូរមនុស្ស ។
- **ប្រទេសដែលមានចំណាត់ថ្នាក់លេខ២៖** ជាប្រទេសដែលមិនអនុវត្តបានពេញលេញនូវបទដ្ឋានអប្បបរមានោះទេ តែបានប្រឹងប្រែងធ្វើសកម្មភាពជាច្រើនគួរឲ្យកត់សម្គាល់ ដោយអនុលោមតាមបទដ្ឋានទាំងនោះ ។
- **ប្រទេសមានចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល៖** ជាប្រទេសដែលមិនអនុវត្តបានពេញលេញនូវបទដ្ឋានអប្បបរមានេះ ហើយតែ ក. ការប៉ាន់ប្រមាណចំនួនជនរងគ្រោះនៃទម្រង់ធ្ងន់ធ្ងរដោយអំពើជួញដូរមនុស្សកើនច្រើនគួរឲ្យកត់សម្គាល់ ហើយប្រទេសនោះ មិនបានធ្វើសកម្មភាពជាក់លាក់ដែលសមាមាត្រនឹងទំហំបញ្ហានេះឡើយ ។ ខ. មានការខកខានមិនផ្តល់ភស្តុតាងនៃការកើនឡើងនូវការប្រឹងប្រែងប្រយុទ្ធប្រឆាំងរាល់ទម្រង់ធ្ងន់ធ្ងរនៃអំពើជួញដូរមនុស្សពីឆ្នាំមុន រួមទាំងការកើនឡើងនូវការស៊ើបអង្កេត ការនាំយកជនល្មើសមកកាត់ទោស និងការផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស ការកើនឡើងនូវការផ្តល់ជំនួយដល់ជនរងគ្រោះ និងការថយចុះនូវភស្តុតាងនៃការចូលដៃរបស់មន្ត្រីរដ្ឋាភិបាលទៅក្នុងទម្រង់ធ្ងន់ធ្ងរនៃអំពើជួញដូរមនុស្ស ។
- **ប្រទេសដែលទទួលចំណាត់លេខ៣៖** ជាប្រទេសដែលមិនបានឆ្លើយតបពេញលេញនូវបទដ្ឋានអប្បបរមា និងមិនមានការប្រឹងប្រែងគួរឲ្យកត់សម្គាល់ដើម្បីធ្វើកិច្ចការនេះទេ ។

➢ តាមគោលការណ៍កំណត់របស់អាមេរិក ប្រទេសដែលទទួលបានលេខ២ក្នុងបញ្ជីឃ្លាំមើលជាប់គ្នាពីរឆ្នាំ អាចធ្លាក់ទៅលេខ៣ បើមិនបង្ហាញពីការខិតខំប្រឹងប្រែង ដែលគួរឲ្យកត់សម្គាល់ទេនោះ ។
➢ ហើយប្រទេសដែលទទួលចំណាត់ថ្នាក់លេខ៣ អាចនឹងទទួលការរឹតបន្តឹងអំពីជំនួយបរទេស ជាពិសេសពីសហរដ្ឋអាមេរិក ដើម្បីជាការដាក់ទណ្ឌកម្ម ។

កន្លងមក ការវាយតម្លៃ ធ្វើឡើងដោយ តាមរយៈការប្រមូលរបាយការណ៍ពីគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលតែងមានការបូកសរុបប្រចាំខែត្រីមាស និងឆ្នាំ ឬពីតាមក្រសួងស្ថាប័នដោយផ្ទាល់ពីភ្នាក់ងារសហរដ្ឋអាមេរិក តែក៏មានរបាយការណ៍ពីអង្គការក្រៅរដ្ឋាភិបាល ដែលស្និទ្ធិនឹងស្ថានទូតអាមេរិក ហើយក៏មានការស៊ើបអង្កេតពីប្រព័ន្ធយកព័តមានដែលមានវត្តមាននៅកម្ពុជា ដែលមានFBI, CIA, ICEជាដើម ។

អាមេរិកទទួលស្គាល់ថា កម្ពុជាបានខិតខំប្រឹងប្រែងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតែហាក់ដូចជាមិនទាន់បានឆ្លើយតបពេញលេញទៅនឹងស្តង់ដា ឬបទដ្ឋានអប្បបរមា (Minimum Standard) នៃច្បាប់ការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស (TVPA: Trafficked Victim Prevention Act.) របស់អាមេរិក។

ស្ទើរតែរៀងរាល់ឆ្នាំ សហរដ្ឋអាមេរិក តែងផ្តោតលើៈ

កិច្ចការផ្តន្ទាទោស ដែលមានរបាយការណ៍យឺតយ៉ាវ និងមិនច្បាស់លាស់ អំពីការផ្តន្ទាទោសអំពើជួញដូរមនុស្ស និងបានចោទប្រកាន់ថាមានអំពើពុករលួយនៅក្នុងប្រព័ន្ធអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ដោយមានមន្ត្រីឃុបឃិតក្នុងប្រព័ន្ធជួញដូរមនុស្ស ។ អាមេរិក បានលើកអនុសាសន៍មួយចំនួន ពាក់ព័ន្ធនឹងការស៊ើបអង្កេតសម្ងាត់ និងការដាក់ទោសទណ្ឌមន្ត្រីឃុបឃិត ។ (ថ្មីៗនេះ ក្រសួងយុត្តិធម៌ បាននិងកំពុងធ្វើកំណែទម្រង់ផ្ទៃក្នុងក្រសួង និងប្រព័ន្ធអយ្យការ ដោយចាត់តាំងរដ្ឋលេខាធិការមួយរូប និងអនុរដ្ឋលេខាធិការមួយរូបទទួលខុសត្រូវ លើបទល្មើសជួញដូរមនុស្ស និងបានពន្លឿនការដោះស្រាយសំណុំរឿងកកស្ទះ នៅតាមសាលាដំបូងរាជធានី ខេត្តយ៉ាងមានប្រសិទ្ធភាព តែនៅប្រព័ន្ធរបាយការណ៍ មានការយឺតយ៉ាវ) ។

ខ្វះការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ដែលអនុវត្តខុសឆ្គង ជ្រើសរើស និងបញ្ជូនខុសគោលការណ៍ច្បាប់ កេងចំណេញ ធ្វើឲ្យពលករចំណាយច្រើនទៅលើការធ្វើឯកសារ អ្នករត់ការ ដែលឃុបឃិតទាមទារកម្រៃ និងតម្លៃខ្ពស់ ធ្វើឲ្យពលករត្រូវជំពាក់បំណុលឯកជន ឬមីក្រូហិរញ្ញវត្ថុ ឬត្រូវលក់របស់ទ្រព្យ ដែលបង្កើតឲ្យមានភាពប្រឈមផ្នែកជីវភាពកាន់តែខ្លាំង និងបែរទៅប្រើប្រាស់ប្រព័ន្ធក្រៅផ្លូវការ និងមិនស្របច្បាប់ ជាមូលហេតុធ្វើឲ្យពលកររងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរនៅប្រទេសគោលដៅ ។ ជា

អនុសាសន៍ អាមេរិកស្នើឲ្យបង្កើនការធ្វើអធិការកិច្ចឲ្យបានហ្មត់ចត់ ដោយដាក់ទោសទណ្ឌលើក្រុមហ៊ុន និងអ្នកឃុបឃិតដើម្បីកាតបន្ថយភាពរងគ្រោះរបស់ពលករ។

កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនមានភាពច្បាស់លាស់ ហើយពឹងពាក់ច្រើនលើសេវាអង្គការសេវាអង្គការមិនមែនរដ្ឋាភិបាល ។ ជាអនុសាសន៍ អាមេរិក គឺស្នើបង្កើការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ជាពិសេសក្រសួងសង្គមកិច្ច លើការលើកកម្ពស់ការកំណត់អត្តសញ្ញាណជនរងគ្រោះ និង ផ្តល់សេវាឲ្យបានជាក់លាក់ ទាំងសេវាផ្នែកច្បាប់ សេវាសង្គម និងការលើកកម្ពស់ជីវភាព (ការងារ មុខរបរ) ដើម្បីកាត់បន្ថយការប្រថុយប្រថានរងគ្រោះជាថ្មី ។ (កន្លងមក សម្តេចប្រមុខរាជរដ្ឋាភិបាល បានបង្កើតក្រុមមេធាវីស្ម័គ្រចិត្ត បាន និងកំពុងជួយការពារក្តីជនក្រីក្រ ជាពិសេស ស្ត្រី និងកុមារ) ។

ពាក់ព័ន្ធនឹងកិច្ចសហការ **លោក ប៉ាទ្រិក ម័រហ្វី** (W. Patrick Murphy) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពសហរដ្ឋអាមេរិក បានដឹកនាំគណៈប្រតិភូ ជួបជាមួយគណៈប្រតិភូអន្តរក្រសួងកម្ពុជា ពីរលើកនៅក្រសួងមហាផ្ទៃ គឺនៅខែតុលា ឆ្នាំ២០២០ ម្តង និងនៅខែមករា ឆ្នាំ២០២១ ម្តង ដោយសន្យាថា នឹងទំនាក់ទំនងជិតស្និទ្ធ ដើម្បីស្វែងយល់ពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជៀសវាងការខុសឆ្គងក្នុងការវាយតម្លៃប្រចាំឆ្នាំ ។ ក្រៅពីនេះ ក្រុមអ្នកបច្ចេកទេស បានជួបជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម ដើម្បីពិភាក្សាអំពីការអនុវត្តអនុសាសន៍ដែលសហរដ្ឋអាមេរិក បានស្នើឡើង សម្រាប់ពង្រឹងការងារដែលនៅខ្វះចន្លោះ ដែលធ្វើឲ្យកម្ពុជា ស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល ដែលអាចនឹងឈានទៅលេខ៣ ដែលជាចំណាត់ថ្នាក់ទាបបំផុត បើមិនមានការប្រឹងប្រែង ។

អង្គការ USAID អាមេរិក បានជួលអ្នកធ្វើរបាយការណ៍ឯករាជ មួយរូប ឲ្យធ្វើការជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ដ ដើម្បីប្រមូលទិន្នន័យដែលជាក់លាក់ និងត្រឹមត្រូវ ។ មកដល់ពេលនេះ របាយការណ៍ត្រូវបានបញ្ជូនទៅស្ថានទូតជាទៀងទាត់ ដោយផ្អែកលើរបាយការណ៍ជាតិ ដែលអគ្គលេខាធិការដ្ឋាន បានរៀបចំ ។ សកម្មភាពការងារជាច្រើន ត្រូវបានបន្តធ្វើឡើងតាមប្រព័ន្ធអនឡាញ ។

## ២. កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ទោះបីជាមានភាពប្រឈមក្នុងការងារប្រឆាំងកូវីដក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការ បានរួមសហការគ្នារវាងក្រសួង ស្ថាប័ន អាជ្ញាធរ សមត្ថកិច្ចនៅថ្នាក់ក្រោមជាតិ ក៏ដូចជាស្ថានទូត ប្រចាំប្រទេសគោលដៅពាក់ព័ន្ធ បានបន្តជម្រុញអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន គឺ (១) ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ (២)

ការបង្ការទប់ស្កាត់ (៣) ការបង្ក្រាប និងផ្តន្ទាទោស និង(៤)កិច្ចការពារជនរងគ្រោះ ដោយមិនមានធ្វេសប្រហែសឡើយ ។

ឆ្នាំ២០២០ ជាឆ្នាំដែលកូវីដ ១៩ បានលុកលុយទូទាំងពិភពលោក និងចូលដល់ព្រះរាជាណាចក្រកម្ពុជា ។ ប្រទេសគោលដៅ ជាពិសេសប្រទេសថៃ ដែលមានពលករកម្ពុជាច្រើននៅទីនោះ ក៏ប្រឈមខ្លាំងនឹងការរាតត្បាតនៃជម្ងឺដ៏កាចសាហាវនេះ ហើយបានធ្វើឲ្យបាត់បង់ការងារ និងប្រាក់ចំណូលរបស់កម្មករកម្មការិនី ជាពិសេស ពលករទេសន្តរប្រវេសន៍ ដែលស្នាក់អាស្រ័យ និងធ្វើការនៅទីនោះ ធ្វើឲ្យមានការវិលត្រឡប់មកប្រទេសកម្ពុជាវិញ ទោះបីមានការបិទព្រំដែនដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជម្ងឺកូវីដ ១៩ ហើយក៏ដោយ ។ ក្នុងឆ្នាំ២០២០ ពលករទេសន្តរប្រវេសន៍កម្ពុជាបានវិលត្រឡប់ រហូតដល់ទៅ ជាង ១៧ម៉ឺននាក់ និងគិតដល់ដំណាច់ខែមេសា ឆ្នាំ២០២១ មាន ១៨៦ ៨៣១នាក់នាំគ្នាត្រឡប់មកវិញ តាមច្រកមិនផ្លូវការនៃបណ្តាខេត្តជាប់ព្រំដែន និងនៅតែបន្តវិលត្រឡប់ជាបន្តបន្ទាប់ទៀត ។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល បានបង្កើនការយកចិត្តទុកដាក់ខ្ពស់ លើការគ្រប់គ្រងលំហូរចេញចូល ការទទួលនិងផ្តល់ការឧបត្ថម្ភគាំទ្រទាំស្បៀងអាហារ ការដឹកជញ្ជូន ការផ្តល់សេវាសាធារណៈដូចប្រជាពលរដ្ឋក្នុងស្រុក ការលើកកម្ពស់ជីវភាព ដែលលើសពីនេះទៅទៀត គឺសេវាសុខភាព ការពិនិត្យ រកពលករដែលឆ្លងកូវីដ ១៩ ការដាក់ឲ្យធ្វើចត្តាឡីស័ក ការព្យាបាល និងអាចការពារបាន ពីការឆ្លងចូលសហគមន៍ និងគ្មានអ្នកស្លាប់ដោយ កូវីដ ១៩ ក្នុងឆ្នាំ២០២០ ។ តែទន្ទឹមនឹងនោះ ក៏នៅតែមានជនខិលខូច ព្យាយាម អូសទាញ បោកបញ្ឆោតពលករឲ្យត្រឡប់ទៅវិញ ក្នុងស្ថានភាពដែលប្រឈមនឹងគ្រោះថ្នាក់ ដោយការដាក់ទោសទណ្ឌ និងការឆ្លងរាលដាលជាលជម្ងឺកូវីដ ១៩ និងធ្វើឲ្យពលកររងគ្រោះជាថ្មីដោយខាតបង់ទ្រព្យធន ពេលវេលា និងជាកម្មវត្ថុនៃអំពើជួញដូរមនុស្ស ។

## សកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស៖

ឆ្នាំ ២០២០ អនុលោមតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) សមត្ថកិច្ចនគរបាលយុត្តិធម៌ (ទាំងនគរបាល ទាំង កងរាជអាវុធហត្ថលើផ្ទៃប្រទេស) បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៥៥**ករណីលើ**១៦៩**ករណី (ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន **១៤**ករណី ស្មើនឹង**៨.២៨%**) ។

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **១៩៣**នាក់/**២២៩**នាក់(ស្រី **៣០**នាក់) ក្នុងនោះ ជនសង្ស័យជាអនីតិជន **១២**នាក់ និងជនបរទេស **២៣**នាក់ មាន **០៨**សញ្ជាតិ សញ្ជាតិអ៊ីស្រាអែល **០១**នាក់ ចិន**១៣**នាក់ អង់គ្លេស**០១**នាក់ វៀតណាម**០៤**នាក់ អាមេរិ **០១**នាក់ ស៊ុយអែត**០១**នាក់ រុស្ស៊ី**០១**នាក់ និងបង់ក្លាដេស**០១**នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **៤៦៧**នាក់/**៤៥៦**នាក់ ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ **១៣០**នាក់ អាយុ ១៥-១៧ឆ្នាំ **៣៩**នាក់ និងអាយុពី១៨ឆ្នាំឡើង **២៩៨**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៩៨**នាក់ និងប្រគល់ឱ្យគ្រួសារ **៣៦៩**នាក់) ។ ក្នុងនោះមានចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស៖** បង្ក្រាបបាន ៤៤ករណី/៣៨ករណី(កើនឡើង ០៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៥៥/៦១**នាក់(ស្រី **១៧**នាក់) ជនបរទេស០៤នាក់ មាន០៤សញ្ជាតិ និងសង្គ្រោះជនរងគ្រោះចំនួន **២៧៦/១៥១**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ **៣១**នាក់ អាយុ១៥-១៧ឆ្នាំ **១៦**នាក់ និងអាយុពី១៨ឆ្នាំឡើង **២២៩**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៣០**នាក់ និងប្រគល់ឱ្យគ្រួសារ **២៤៦**នាក់)។

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ៖** បង្ក្រាបបាន **១១១**ករណី/**១៣១**ករណី(ថយចុះ **២០**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៣៨/១៦៨**នាក់ (ស្រី **១៣**នាក់) អនីតិជន **១២**នាក់ ជនបរទេស **១៩**នាក់ មាន **០៤**សញ្ជាតិ ។ សង្គ្រោះជនរងគ្រោះចំនួន **១៩១/៣០៥**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ **៩៩**នាក់ អាយុ១៥-១៧ឆ្នាំ **២៣**នាក់ និងអាយុពី១៨ឆ្នាំឡើង **៦៩**នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច **៦៨**នាក់ និងប្រគល់ឱ្យ គ្រួសារ **១២៣** នាក់)។




**ត្រីមាសដើមឆ្នាំ ២០២១៖** សមត្ថកិច្ច បានបង្ក្រាបករណីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ច្រើនជាងឆ្នាំកន្លងទៅ គឺ៖

បើគិតពីថ្ងៃទី១៣ខែកុម្ភៈ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ (រយៈពេល ៨៧ថ្ងៃ)តាមរបាយការណ៍អគ្គស្នងការនគរបាលជាតិ៖

បង្ក្រាបមេខ្យល់បាន ១២២ករណី មានមនុស្ស ១៨៤នាក់ ស្រី១៣នាក់ ក្នុងនោះ ៖

- ខេត្តបន្ទាយមានជ័យ ៤៥ករណី មនុស្ស ៧០នាក់ ស្រី ០៧នាក់
- ខេត្តបាត់ដំបង ៣៧ករណី មនុស្ស ៥១នាក់ ស្រី ០៣នាក់

- ខេត្តឧត្តរមានជ័យ ០៧ករណី មនុស្ស ០៧នាក់
- ខេត្តព្រៃវែង ០១ករណី មនុស្ស ០៥នាក់ ស្រី០១នាក់
- ខេត្តប៉ៃលិន ០៣ករណី មនុស្ស ០៣នាក់
- ខេត្តកោះកុង ១៤ករណី មនុស្ស ១៦នាក់
- ខេត្ត មណ្ឌលគីរី ០១ករណី មនុស្ស ០១នាក់
- រាជធានីភ្នំពេញ ០២ករណី មនុស្ស ០៤នាក់ ស្រី ០១នាក់
- ខេត្តកណ្តាល ០២ករណី មនុស្ស ០៤នាក់
- ខេត្តតាកែវ ០២ករណី មនុស្ស ០៩នាក់
- ខេត្តស្វាយរៀង ០៦ករណី មនុស្ស១៣នាក់ ស្រី ០១នាក់
- ខេត្តត្បូងឃ្មុំ ០២ករណី មនុស្ស ០១នាក់ ។

រកឃើញមនុស្សសរុប និងបញ្ជូនទៅធ្វើចត្តាឡីស័ក ៦ ១៨០នាក់ ស្រី ១៥៩៤នាក់ ។

ករណីភាគច្រើន ពាក់ព័ន្ធនឹងការនាំមនុស្សចេញខុសច្បាប់ ដើម្បីឆ្លងដែន នៅក្នុងដំណាក់កាលដែលប្រទេសទាំងឡាយ កំពុងរឹតបន្តឹងការចេញចូលឆ្លងដែន និងមិនទាន់មានការជ្រើសរើសពលករជាថ្មីនៅឡើយ (ការនាំមនុស្សចេញទៅប្រទេសជិតខាង ដែលប្រឆាំងនឹងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអំពើអាជីវកម្មផ្លូវភេទផង និងច្បាប់ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់កូវីដ ១៩ ផង)។ ករណីមួយចំនួនទៀត ពាក់ព័ន្ធនឹងការសង្គ្រោះជនរងគ្រោះ ដែលត្រូវបានរងគ្រោះនៅប្រទេសគោលដៅ (ជាពិសេស ស្ត្រីរងគ្រោះដែលត្រូវបានគេបោកបញ្ឆោតទៅរកគូស្រករ ឬទៅធ្វើការនៅប្រទេសចិន) ។

ការបង្ក្រាបនេះ ក៏មានរហូតដល់ការបង្ក្រាបជនសង្ស័យដែលជាមន្ត្រីថ្នាក់ឧត្តមសេនីយ៍ទៀតផង ។

- យោងតាមលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនជនសង្ស័យថារងគ្រោះ សរុបចំនួន ៨៦នាក់ (ប្រុស០១ អនីតិជន០២) ក្នុងនោះ៖
  - មកពីប្រទេសចិន ៥៨នាក់ (ប្រុស០១)
  - មកពីប្រទេសសិង្ហបុរី ០៣នាក់ (ស្រី០៣)
  - មកពីប្រទេសម៉ាឡេស៊ី ២៥នាក់ (អនីតិជន ០២)។

បញ្ជូនទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ធ្វើការសម្ភាសចំនួន៥០នាក់ ។ បន្ទាប់ពីសម្ភាសន៍ចប់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានី។

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការបង្ក្រាប និងសង្គ្រោះជនរងគ្រោះបានចំនួន ២៣៤នាក់ និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានី ចំនួន២៥នាក់ និងបានបញ្ជូនទៅសហគមន៍ ២០៩នាក់។

- ក្រសួងសង្គមកិច្ច ទទួលជនរងគ្រោះសរុប ៨៤នាក់ (មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចំនួន៧៥នាក់)។

ជាទិសដៅ និងកំពុងអនុវត្តៈ

១- តាមដាន និងជំរុញអនុវត្តផែនការសកម្មភាព ឆ្នាំ២០២១ (កំណត់ដោយផែនការយុទ្ធសាស្ត្រ ជាតិ៥ឆ្នាំ ២០១៩-២០២៣) ស្តីពី «ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

២- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានស្រាប់ និងបន្តរៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្តដទៃទៀត ដែលជាតម្រូវការចាំបាច់ សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

៣- បន្តពង្រឹងយន្តការដឹកនាំបញ្ជា ដោយធ្វើការប្រជុំដាក់ចេញគោលការណ៍ និងចង្អុលណែនាំ គ្រប់ក្បាលម៉ាស៊ីនដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងប្រសិទ្ធភាព ទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និង អភិវឌ្ឍន៍សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខជាប្រចាំ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់។

៤- បន្តពង្រឹងកិច្ចសហការជាមួយយន្តការអន្តរជាតិ យន្តការតំបន់ (អាស៊ាន និងមហាអនុតំបន់ មេគង្គ) និងយន្តការទ្វេភាគីរបស់ប្រទេសពាក់ព័ន្ធ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ អន្តរជាតិ ក្នុងការរៀបចំយន្តការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ ការងារឆ្លងដែនមិនប្រក្រតី និងការការពារផលប្រយោជន៍ពលករនៅក្នុងប្រទេសគោលដៅ។

៥. បន្តពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងប្រព័ន្ធបញ្ជូន ដើម្បីជាមូលដ្ឋាននៃប្រព័ន្ធទិន្នន័យសម្រាប់កិច្ចការពារជនរងគ្រោះ ។

៦. បង្កើនការស្រាវជ្រាវ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេស ការនាំមនុស្សឆ្លងដែនខុសច្បាប់ ដែលជាមូលហេតុនៃភាពរងគ្រោះ ដោយអំពើជួញដូរ និងកេងប្រវ័ញ្ច ។

៧. ពង្រឹងការប្រមូល ចងក្រង និងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ថ្នាក់ជាតិ ពាក់ព័ន្ធនឹងកិច្ចការពារជនរងគ្រោះ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។

៨. ត្រៀមសម្ភោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលទទួលពលករកំរៀង (ខេត្តបាត់ដំបង) ព្រមទាំង បណ្តុះបណ្តាលមន្ត្រីទទួលខុសត្រូវ និងបំពាក់សម្ភារ ដើម្បីដំណើរការមណ្ឌល ។

៩- តាមដាន និងជំរុញការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ទាំងនៅថ្នាក់ជាតិ និងជាអន្តរជាតិ ដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ដ៏ខ្ពង់ខ្ពស់បំផុត ។

ថ្ងៃ សុក្រ ២ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ពស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២១

**ជ. គណៈកម្មាធិការជាតិ គ.ជ.ប.ជ**

**អនុប្រធានអចិន្ត្រៃយ៍**

ង៉ូ ម៉ុនអេង